# តើជារណ្តៅសាកសពមន្ត្រីជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរមែនឬទេ? រណ្តៅសាកសពនៅឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល

ផេង ពង្សរ៉ាស៊ី និង អ៊ូច សំអឿន
មជ្ឈមណ្ឌលឯកសារកម្ពុជា

អត្ថបទសារពត៌មានភ្នំពេញប៉ុស្តិ៍ចេញផ្សាយថ្ងៃទី៩-២២ ខែវិច្ឆិកា ឆ្នាំ២០០១ ក្រោមចំណងជើង "Grave of 800 Khmer Republic officials cited" បានរៀបរាប់ថា មានទាហានសំខាន់ៗនៃរបបសាធារណរដ្ឋខ្មែរចំនួន៨០០នាក់បានស្លាប់នៅក្នុងរណ្តៅមួយដែលមានទីតាំងស្ថិតនៅ ខាងលិចព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល បន្ទាប់ពីមានការកាន់កាប់ទាំងស្រុងនៃរបបកម្ពុជាប្រជាធិបតេយ្យកាលពីខែមេសា ឆ្នាំ១៩៧៥ ។ ក្នុងអត្ថបទដដែល បានបញ្ជាក់ពីការទទួលបានពត៌មានមួយថា មានមន្ត្រីថ្នាក់កំពូលនៃរបបសាធារណរដ្ឋខ្មែរមួយចំនួនដូចជាលោកឡុង បូរ៉េត លោកលន់ ណុន លោក ហង់ ធុនហាក់ និងលោកឈឹម ឈួន ក៏បានមកស្លាប់នៅក្នុងរណ្តៅតែមួយជាមួយទាហានឯទៀត នៃរបបសាធារណរដ្ឋខ្មែរដែរ ។

ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅធ្វើការស្រាវជ្រាវទៅលើទីតាំងសម្លាប់ទាំងនេះ ។ ពត៌មានដែលក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានគឺមានដូចខាងក្រោមៈ

ស្រុកពញាឮមានចម្ងាយ៣០គីឡូម៉ែត្រពីភ្នំពេញ និងចម្ងាយ៤២គីឡូម៉ែត្រពីទីរួមខេត្តកណ្តាល ។ ស្រុក ពញាឮជាតំបន់វាលរាប, មានភ្នំដោយកន្លែង និងមានទន្លេសាបហូរកាត់ ។ ព្រំប្រទល់ស្រុកពញាឮគឺ ខាងលិច ជាប់នឹងស្រុកខដុត្ត ខេត្តកំពង់ស្ពឺ ខាងកើតជាប់នឹងស្រុកបាធាយ ខេត្តកំពង់ចាម ខាងជើងជាប់នឹងស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងខាងត្បូងជាប់នឹងស្រុកឫស្សីកែវ រាជធានីភ្នំពេញ ។ ប្រជាជនក្នុងស្រុកមាន ប្រកបមុខរបរជាអ្នកធ្វើស្រែ(ស្រែប្រាំងនិងវស្សា) ឡើងត្នោត សិប្បកម្ម ចម្ការនេសាទ និងដាំដំណាំ ចំការ ។ សម័យខ្មែរក្រហម ស្រុកនេះជាស្រុក២៥ តំបន់៣២ ភូមិភាគបស្ចិម ។ ក្នុងចំណោមឃុំទាំង១៤. មានឃុំមួយឈ្មោះឃុំសំរោង ជាពិសេសត្រង់ចំណុចផ្លូវគ្រួសក្រហមទី២(ទិសដៅចុះពីផ្សារព្រែកព្នៅប្រហែល ជាងមួយគីឡូម៉ែត្រ) ត្រូវបានក្លាយជាកន្លែងប្រយុទ្ធគ្នាយ៉ាងក្តៅគគុករវាងទាហានខ្មែរក្រហម និងទាហាននៃរបបសាធារណរដ្ឋខ្មែរកាលពីអំឡុងដើមខែមេសា ឆ្នាំ១៩៧៥ ។ បន្ទាប់ពីធ្លាក់ក្នុងការកាន់កាប់របស់ខ្មែរក្រហម ទីតាំងនេះ បានក្លាយទៅជាកន្លែងសម្លាប់មនុស្សមួយយ៉ាងសាហាវបំផុតនាចុងខែមេសាឆ្នាំ១៩៧៥ ។ ក្នុងបរិវេណដីមាត់បឹងប្រហែលជាង៣០០ម៉ែត្រពីផ្លូវគ្រួសក្រហម មានទីតាំងសម្លាប់ចំនួនពីរកន្លែងដែលត្រូវបានស្គាល់យ៉ាងច្បាស់ពីប្រជាជនស្ទើរគ្រប់រូបដែលបច្ចុប្បន្នរស់នៅក្នុងភូមិសំរោងត្បូង ឃុំសំរោង ស្រុកពញាឮ ។

នៅមានកន្លែងតម្កល់អដ្ឋិធាតុមួយកន្លែងទៀតដែលស្ថិតនៅក្នុងទីធ្លាវត្តអង្គសេរីសួស្តី ឃុំសំរោង ស្រុកពញាឮ ។ ទីតាំងសម្លាប់ទាំងពីរកន្លែងនោះគឺៈ

**១) ប្រឡាយតាប៉ិ** លេខកូតភូមិសាស្រ្តៈ ០៨០៩០៥

រយៈកំពស់ (N)$11^{0}$39' 53:64

រយៈទទឹង (E)$104^{0}$50' 34:65

ប្រឡាយតាប៉ិ ត្រូវបានជីកឡើងចាប់ពីចិញ្ចើមផ្លូវរហូតដល់មាត់បឹងនាជំនាន់សង្គមរាស្រ្តនិយមដើម្បីស្តុបនិងបង្ហូរទឹកទៅស្រោចស្រប់សន្ទូង និងសំណាបរបស់ប្រជាជន ។ ប្រឡាយនេះមានទំហំទទឹងប្រហែល២ម៉ែត្រ បណ្តោយប្រហែល៣០០ម៉ែត្រ និងជម្រៅ១,៥ម៉ែត្រ ។ បច្ចុប្បន្នប្រឡាយតាប៉ិនៅមានស្លាកស្នាមនៅឡើយ ប៉ុន្តែដោយសាររាជរដ្ឋាភិបាលបច្ចុប្បន្នតម្រូវឲ្យមានការស្តុបទឹក ដើម្បីធ្វើស្រែប្រាំង ប្រឡាយតាប៉ិត្រូវលិចទឹកគ្រប់រដូវ ។ លោកប្រធានភូមិសំរោងត្បូងបានមានប្រសាសន៍ថា «អាចមើលឃើញស្លាកស្នាមប្រឡាយតាប៉ិនៅខែមិថុនា និងកក្កដារាល់ឆ្នាំ» ។ ស្ថិតក្នុងការក្តោបក្តាប់របស់ខ្មែរក្រហម ប្រឡាយតាប៉ិបានត្រូវជ្រើសរើសយកធ្វើជាកន្លែងសម្លាប់ និងដាក់សាកសពប្រជាជនដែលជម្លៀសចេញពីភ្នំពេញទាំងគ្រួសារៗបូករួមទាំងទាហាននៃរបបសាធារណរដ្ឋខ្មែរដែលភាគច្រើនជាអ្នកដែលមានបណ្តាសក្តិធំៗ ។ គួររំលឹកដែរថាក្រោយថ្ងៃ១៧មេសាឆ្នាំ១៩៧៥ ប្រជាជនទាំងអស់ ជាពិសេសប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញសុទ្ធតែត្រូវបានជម្លៀសចេញទៅកាន់តំបន់ដាច់ស្រយាលឆ្ងាយពីទីក្រុងភ្នំពេញតាមច្រកផ្លូវផ្សេងៗពីគ្នា ។ ចំណែកផ្លូវជាតិលេខ៥ មានការកកស្ទះយ៉ាងសម្បើមនូវព្រឹត្តិការណ៍ជម្លៀសអ្នកភ្នំពេញទៅកាន់ខេត្តបាត់ដំបង ពោធិ៍សាត់ និងទីជនបទនានាដែលមិនមែនជាទីប្រជុំជន ។ ប្រជាជនខ្លះត្រូវបានដឹកតាមឡាន អ្នកខ្លះត្រូវបង្ខំដោយកាណុងកាំភ្លើងឲ្យដើរថ្មើរជើង ។ ដោយមានភាពអំណត់អត់ធន អ្នកខ្លះបានធ្វើដំណើររហូតដល់គោលដៅ ចំណែកខ្លះទៀតត្រូវបញ្ចប់ជីវិតតែក្នុងរយៈពេលខ្លីបំផុតបន្ទាប់ពីមានការសួរដេញដោលពីទ័ពខ្មែរក្រហម ។ លោកពូកាន់កន អាយុ៥៦ឆ្នាំ បានមានប្រសាសន៍ថា មានការដេជីកសួរចម្លើយរកអ្នកដែលមានមុខងារ ឬបណ្តាសក្តិដើម្បីប្រគល់ការងារឲ្យធ្វើវិញ ។ មានប្រជាជនខ្លះដោយពិបាកក្នុងការធ្វើដំណើរ ក៏ត្រូវឆ្លើយតាមត្រង់ ព្រោះត្រូវបន្តរស់នៅទីក្រុងភ្នំពេញតទៅទៀត ។ លោកអ៊ីអ៊ិន ជឹម បានប្រាប់ថា គាត់បានស្លាប់ក្មួយម្នាក់នៅក្នុងប្រឡាយតាប៉ិនេះ ដោយសារតែក្មួយរូបនោះចាញ់បោកខ្មែរក្រហមឆ្លើយតាមត្រង់ថាខ្លួនពាក់សក្តិ២ក្នុងរបបសាធារណរដ្ឋខ្មែរ ។ លោកតាបានសង្កត់ធ្ងន់ថា ប្រជាជនទាំងអស់ត្រូវតែជម្លៀសទៅកាន់ទីជនបទដោយមិនអាចប្រកែកបាន ព្រោះជាបញ្ជារបស់អង្គការ ។ ប្រសិនបើមានការប្រកែក ឬមិនព្រមទៅ គឺប្រាកដជាត្រូវឡើងឡាន ហើយត្រូវសម្លាប់គ្មានសល់មួយនៅក្នុងប្រឡាយតាប៉ិនេះ ។ ចំណែកឯទាហានវិញ លោកតាប្រាប់ថា គ្មានការសួរនាំអ្វីទាំងអស់ ឲ្យតែដឹងថាជាទាហាន គឺចាប់យកមកសម្លាប់ចោលនៅប្រឡាយតាប៉ិដូចគ្នា ។

លោកតាបាននិយាយពីមូលហេតុនៃការសម្លាប់ទាហានថា មកពីទាហានទាំងនោះជាបរិវារដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក ។ លោកពូស៊ិន ទូចបានរៀបរាប់ថា អ្នកជម្លៀសត្រូវបណ្តេញឲ្យចុះពីលើឡាន ហើយចងទាំងខ្សែៗ បណ្តើរមកសម្លាប់នៅក្នុងបរិវេណជ្រលងគ្រើង ឬប្រឡាយតាប៉ុនេះ ។ ចំណែកទាហានដែលមានចាប់ពីសក្តិ២ សក្តិ៣ សក្តិ៤ សក្តិ៥ និងមេធំៗបូករួមទាំងគ្រួសារៗ ក៏ត្រូវយកមកសម្លាប់នៅប្រឡាយតាបិនេះទាំងអស់ ។ មិនតែប៉ុណ្ណោះ ព្រមទាំងមានការតាមរកចាប់ខ្លួនទាហាននៃរបបសាធារណរដ្ឋខ្មែរដែលគេចខ្លួនទៀត ។ ស្ថិតក្នុងកាលៈទេសៈវឹកវរ ទាហានមួយចំនួនបានត្រូវដោះខោអាវទាហានចេញ ហើយរត់មកជ្រកកោនជាមួយប្រជាជនស៊ីវិលធម្មតាដើម្បីគេចពីការរតាមសម្លាប់ ។ ប៉ុន្តែក៏មានមួយចំនួនត្រូវខ្មែរក្រហមតាមចាប់មកសម្លាប់ដោយមិនអាចតវ៉ាបានដែរ ។ លោកពូអួង អន អាយុ៥៥ឆ្នាំ រស់នៅភូមិទួលសាគរ ឃុំសំរោង ស្រុកពញាឮ បាននិយាយពីការចាប់ខ្លួន ទាហានសក្តិ៥ម្នាក់ប្រាប់ថា ថ្ងៃមួយនៅពេលដែលគាត់រួមទាំងគ្រួសារកំពុងសម្រាកនៅក្នុងខ្ទមរបស់គាត់ក្នុងពេលដែលគាត់កំពុងត្រូវបានឲ្យជម្លៀសទៅកាន់ខេត្តបាត់ដំបង

ស្រាប់តែបានឃើញទាហាន

ខ្មែរក្រហមមួយក្រុមដើរតម្រង់ឆ្ពោះទៅចាប់មនុស្សម្នាក់ដែលជាអតីតទាហានសក្តិ៥

នៃរបបសាធារណរដ្ឋខ្មែរ ។ ភ្លាមនោះលោកពូបានសួរទៅក្រុមខ្មែរក្រហមនោះថា «តើចាប់គាត់មានកំហុសអី» ក្រុមខ្មែរក្រហមនោះបាន និយាយប្រាប់ថា «អាម្នាក់នេះជាទាហានសក្តិ៥របស់អាលន់ណុលទុកវាមិនបានទេ» ។ លោកពូអួង អនបានតាមមើលរហូតទាល់តែមានការបាញ់រះជាច្រើនគ្រាប់ទៅលើបុរសនោះ ហើយទំលាក់ចូលក្នុងប្រឡាយតាប៉ុ ។ ក្រោយពីហេតុការណ៍បានបញ្ចប់ប៉ុន្មានថ្ងៃ លោកពូអួង អនបានធ្វើដំណើរបន្តតាមផ្លូវជាតិលេខ៥ឆ្ពោះទៅកាន់ខេត្តបាត់ដំបងតាមបញ្ជាដាច់ខាតមួយ ។ លោកពូ ជុំ សាមឿន ជាអនុប្រធានភូមិសំរោងត្បូង ឃុសំរោង ស្រុកពញាឮ ខេត្តកណ្តាល បានប្រាប់ពីចំនួនសាកសពដែលបានស្លាប់នៅក្នុងប្រឡាយតាប៉ុថា មានចំនួនជាងមួយពាន់នាក់ ។ ការសម្លាប់មនុស្សនៅក្នុងប្រឡាយតាប៉ុនេះ ត្រូវបានបញ្ចប់នៅចុងឆ្នាំ១៩៧៥ បន្ទាប់ពីមានការជម្លៀសប្រជាជនអស់ពីទីក្រុងភ្នំពេញ និងលែងមានការសង្ស័យថានៅមានទាហាននៃរបបសាធារណរដ្ឋខ្មែរតទៅទៀត ។

ចាប់ពីឆ្នាំ១៩៧៦រហូតមកដល់ថ្ងៃរំដោះ៧មករា១៩៧៩ ការសម្លាប់មនុស្សនៅប្រឡាយតាបិ ត្រូវបានបញ្ឈប់ និងប្រែក្លាយកន្លែងនោះទៅជាកន្លែងធ្វើស្រែប្រចាំសហករណ៍វិញ ។ មនុស្សដែលបានស្លាប់នៅក្នុងប្រឡាយតាប៉ុទាំងអស់ សុទ្ធតែត្រូវបានសម្លាប់ដោយការបាញ់រះភ្លាមៗបន្ទាប់ពីចាប់បាន ។ គ្មានមន្ទីរឃុំឃាំង ឬមន្ទីរអប់រំកែប្រែឡើយសម្រាប់អ្នកទាំងនោះ ។ មានទាហាននៃរបបសាធារណរដ្ឋខ្មែរជាច្រើននាក់ត្រូវមកបញ្ចប់ជីវិតរបស់ខ្លួននៅក្នុងប្រឡាយតាបិ រួមជាមួយប្រជាជនមួយចំនួនដែលមិនព្រមគោរពតាមបញ្ជា

ដាច់ខាតរបស់ខ្មែរក្រហម ។ លោកពូកាន់ កន និងលោកតាអ៊ិញ ជឹម បានមានប្រសាសន៍ថា ចំនួនអ្នកស្លាប់នៅប្រឡាយតាប៉ិនេះ គឺមានទាហានស្លាប់ច្រើនជាងប្រជាជនធម្មតា ។ លោកពូកាន់ កន បាននិយាយពីមូលហេតុថា ទីមួយស្លាប់ដោយសារការបាញ់គ្នា ហើយក្រោយមកត្រូវសែងមកបោះចោលនៅក្នុងប្រឡាយនេះ និងទីពីរស្លាប់ដោយសារការចម្រាញ់តាមរយៈការសួរចម្លើយ និងការតាមចាប់ខ្លួន ។ ចំណែកប្រជាជនធម្មតាវិញមានមួយភាគតូចដែលបានស្លាប់ដោយសារសង្គ្រាម និងមួយភាគតូចទៀតដោយសារការរឹងទទឹងមិនស្តាប់បទបញ្ជាខ្មែរក្រហម ។

***២) ទីតាំងសម្លាប់លូតាគង់ ឬទ្វារទឹក*** *លេខកូតភូមិសាស្ត្រ: ០៨០៩០៦*

*រយៈកំពស់* (N)$11^{0}$39' 32:93

*រយៈទទឹង* (E)$104^{0}$48' 30:68

លូតាគង់ ឬទ្វារទឹក ត្រូវបានសាងសង់ឡើងក្រោមដួវគ្រួសក្រហមមួយខ្សែដែលលាតសន្ធឹងពីផ្លូវជាតិលេខ៥ត្រង់ផ្សារព្រែកព្នៅរហូតដល់ផ្លូវជាតិលេខ៤ ត្រង់ផ្សារបែកចាន ។ ប្រជាជនដែលរស់នៅក្នុងភូមិសំរោងត្បូង និងប្រជាជនដែលរស់នៅក្នុងឃុំព្រែកព្នៅមួយចំនួន បានពឹងផ្អែកទាំងស្រុងទៅលើការបិទបើកទ្វារទឹកនៃលូតាគង់នេះ ព្រោះទឹកនារដូវតម្លើងត្រូវបានទប់ទុកនៅក្នុងបឹងប៉ែកខាងត្បូងផ្លូវគ្រួសក្រហមមួយខ្សែនេះដោយទ្វារទឹកនៃលូតាគង់ ។ ទឹកដែលស្តុបនោះ ត្រូវចែកចាយបញ្ចូលតាមស្រែនារដូវប្រាំង ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លូទឹកមួយនេះត្រូវបានបិទ ដើម្បីធ្វើជាកន្លែងសម្លាប់ និងកន្លែងទំលាក់សាកសពក្រោយពីការ ប្រយុទ្ធគ្នារវាងទាហានខ្មែរក្រហម និងទាហាននៃរបបសាធារណរដ្ឋខ្មែរ ។ កេត ចន្ថា អាយុ៣៨ឆ្នាំ បច្ចុប្បន្ន ជាកម្មករលីសែងនៅភូមិព្រែកព្នៅ ឃុំព្រែកព្នៅ ស្រុកពញាព្ញ បានរៀបរាប់ប្រាប់ថា គាត់បានដឹងថាជាកន្លែង ដែលសម្លាប់មនុស្សដោយសារគាត់បានដើរទៅរើសអេតចាយដល់កន្លែងសម្លាប់នោះ(លូតាគង់ឬទ្វារទឹក) ។ ចន្ថា មានការសប្បាយចិត្តយ៉ាងខ្លាំងចំពោះការរើសសំបកកាទុះគ្រាប់កាំភ្លើងបានច្រើន ។ ដោយចិត្តលោភលន់របស់គាត់ បានធ្វើឲ្យគាត់សម្រេចចិត្តលោតចុះទៅក្នុងលូដើម្បីរាវរកសំបកគ្រាប់ ។ ប៉ុន្តែបំណងរបស់គាត់ត្រូវខកខានវិញ ព្រោះរាវប៉ះសុទ្ធតែឆ្អឹងខ្មោច និងលលាដ៏ក្បាលខ្មោច ។ ចន្ថាបន្តថា “មានលលាដ៏ក្បាលខ្លះនៅមានសក់នៅជាប់នៅឡើយ ហើយមានទាំងក្អួយ និងកន្ទេលផង” ។ ចន្ថា បានបន្តសំដីរបស់គាត់ទៀតថា “គ្រាន់តែខ្ញុំលើកមកដាក់រៀបនៅខាងលើ មានចំនួនប្រហែល៥០ក្បាល” ។ ប្រភេទជនរងគ្រោះដែលបានស្លាប់នៅកន្លែងនេះ គឺមានភាគច្រើនជាទាហានដែលស្លាប់ដោយសារសង្គ្រាមកាលពីអំឡុងដើមឆ្នាំ១៩៧៥ ។

***៣) បូជនីយដ្ឋានវត្តអង្គសេរីសួស្តី*** *លេខកូតភូមិសាស្ត្រ: ០៨០៩០៤*

*រយៈកំពស់* (N)$11^{0}$40' 58:14

រយៈទទឹង (E)104$^{0}$49' 56:40

មានអដ្ឋិធាតុចំនួនពីររទេះត្រូវបានដឹកយកទៅតម្កល់នៅក្នុងបរិវេណវត្តអង្គសេរីសួស្តី បន្ទាប់ពីមានការដឹកកកាយនៅទីតាំងសម្លាប់ប្រឡាយតាប៉ិនិងទ្វារទឹក ។ មានមនុស្សចំនួនបីនាក់បានអះអាងថាជាអ្នកដឹកអដ្ឋិធាតុទាំងនោះមកកាន់ទីវត្ត ។ ប៉ុន្តែមានមនុស្សស្ទើរតែមួយភូមិសំរោងត្បូង បានផ្ដើលមកជីករណ្ដៅដែលជាប្រឡាយតាប៉ិដើម្បីស្វែងរកលាភសក្ការៈផ្សេងៗដែលបន្សល់ជាប់នៅក្នុងខ្លួនសាកសពដែលរលួយស្អុយស្ទើរចូលជិតមិនបាន ។ ព្រឹត្តិការណ៍ទាំងនេះ បានកើតឡើងនៅក្នុងអំឡុងពេលនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបង្កើតឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានសមមិត្តកែវ ចិន្តាជាប្រធានតុលាការ ។ ថ្វីត្បិតតែការគាស់ប្រឡាយនេះដើម្បីស្វែងរកមាសប្រាក់ ប៉ុន្តែនេះក៏ជាបច្ច័យមួយក្នុងការបង្ហាញយ៉ាងច្បាស់ពីការសម្លាប់រង្គាលដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនៅស្រុកពញាព្រុ ។ លោកពូជឹម នៅ អាយុ៨១ឆ្នាំបាននិយាយថា "ខ្ញុំបានឃើញឆ្អឹងច្រើនណាស់" ។ លោកពូនិយាយបន្តថា ឆ្អឹងមានចំនួនច្រើនពាសពេញដីមានទាំងនៅក្នុងប្រឡាយ និងនៅក្រៅប្រឡាយ បូករួមទាំងនៅសងខាងផ្លូវផង ។ រណ្ដៅខ្លះលោកពូសង្កេតឃើញមាននៅសេសសល់ខោអាវនៅរុំជាប់នឹងឆ្អឹងនៅឡើយ ទោះជាមានការរឡេះរលួយសាច់អស់ក៏ដោយ ។ កន្លែងខ្លះទៀតគាត់សង្កេតឃើញមានស្បែកជើងទាហាន ផ្លាកសញ្ញារបស់ទាហាន និងខោអាវទាហានដែរ ។ ចំណែកលោកពូ សាមឿន បានបញ្ជាក់ប្រាប់ថា ប្រជាជនក្នុងភូមិសំរោងត្បូងស្ទើរតែទាំងអស់បាននាំគ្នាទៅគាស់រកអេតចាយដូចជាសំបកកាំទុះកាំភ្លើង និងគ្រឿងគ្រោផ្សេងទៀតនៅកន្លែងសម្លាប់របស់ខ្មែរក្រហម ព្រោះប្រជាជនទាំងនោះយល់ថា ជាកន្លែងដែលធ្លាប់បានពើបប្រយុទ្ធគ្នារវាងទាហានលន់ ណុល និងទាហានខ្មែរក្រហមកាលពីជិតបែកទីក្រុងភ្នំពេញថ្ងៃ១៧មេសាឆ្នាំ១៩៧៥ ។ លុះគាស់ទៅខ្លះរើសបានមាស និងខ្លះទៀតរើសបានសំបកកាំទុះកាំភ្លើងធំតូចជាច្រើនគ្រាប់ ។ ចំណែកឯសាកសពដែលរឡេះរលួយនៅក្នុងរណ្ដៅដែលជាប្រឡាយតាប៉ិនោះ ក៏ត្រូវបានគាស់រើយកឆ្អឹងមកដាក់នៅខាងលើមាត់រណ្ដៅរហូតទាល់តែមានការយកទៅតម្កល់ទុកនៅវត្តអង្គសេរីសួស្តី ដែលមានទីតាំងមិនឆ្ងាយប៉ុន្មានពីទីតាំងសម្លាប់ ។ វត្តអង្គសេរីសួស្តី ស្ថិតនៅក្នុង ភូមិសំរោងត្បូង ឃុំសំរោង ស្រុកពញាព្រុ ខេត្តកណ្ដាល ។

លោកតា អ៊ិញ ជឹម អាយុ៦៥ឆ្នាំ រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកពញាព្រុ ខេត្តកណ្ដាល ដែលជាអ្នកដឹកអដ្ឋិធាតុផ្ទាល់ពីទីតាំងប្រឡាយតាប៉ិមកតម្កល់នៅក្នុងចេតិយ៍មួយក្នុងវត្តអង្គសេរីសួស្តី បានប្រាប់ថា គាត់បានដឹកតាមរទេះក្របីចំនួនមួយរទេះ ។ លោកតាបន្តថា គាត់ដឹកបានតែមួយទេះទេ ប៉ុន្តែឆ្អឹងដែលនៅសល់នោះគឺមានចំនួនច្រើនណាស់ ។ លោកប្រធានភូមិសំរោងត្បូង បានមានប្រសាសន៍ថា ប្រឡាយតាប៉ិទាំងមូលមិនត្រូវបានដឹកទាំងអស់ទេ គឺបានដឹកត្រឹមមួយភាគបីនៃប្រឡាយប៉ុណ្ណោះ ។ រហូតមកដល់បច្ចុប្បន្ន នៅមានឆ្អឹងច្រើនណាស់មិនត្រូវបានគាស់យកមកតម្កល់ ។ ចំណែកឆ្អឹងដែលបានយកមកតម្កល់ គឺបានបាត់បង់

អស់ជាងពាក់កណ្ដាលទៅទៀតដោយសារសត្វស៊ី និងការផ្លាស់ប្ដូរទីតាំង ។ បច្ចុប្បន្នគណៈកម្មការវត្តអង្គសេរីសួស្ដីបានសាងសង់បូជនីយដ្ឋានថ្មីមួយនៅប៉ែកខាងជើងវត្តក្បែរស្រះឈូកមួយ ដើម្បីដាក់អដ្ឋិធាតុដែលនៅសេសសល់ពីការបំផ្លាញ ។

ដេង ពង្សរ៉ាស៊ី និង អ៊ូច សំអឿន
មជ្ឈមណ្ឌលឯកសារកម្ពុជា